**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមប្រឹក្សា
កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
អគ្គលេខាធិការដ្ឋាន
លេខៈ០១៨/០៩ រប.កកចយ

# របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំឆមាសទី១ ឆ្នាំ ២០០៩ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ចាប់ពីខែ មករា ដល់ខែមិថុនា ឆ្នាំ ២០០៩ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមាន អង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានដំណើរការការងាររបស់ខ្លួនស្របតាម បេសកកម្មដែលបាន កំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផល ជាក់ស្តែងដូចខាងក្រោម ៖

## ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌

### ក. ការងាររដ្ឋបាល

- ទទួលលិខិតស្នើចាត់តាំងសមាជិកក្នុងក្រុមការងារបច្ចេកទេសចម្រុះ ស្តីពីភាពជាដៃគូ និងសុខុមដុមនីយ កម្មពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៩
- ទទួលលិខិតអញ្ជើញពីទីស្តីការគណៈរដ្ឋមន្ត្រី ដោយអញ្ជើញនាយកអង្គភាពគ្រប់គ្រង គម្រោងគម្រោង ជាកិត្តិយសដែលឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី ទទួលជួបប្រធានធនាគារពិភពលោកថ្មីទទួលបន្ទុកប្រទេសកម្ពុជា ដែលនឹង ប្រព្រឹត្តទៅ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី (អតីតរដ្ឋសភា)
- ទទួលបានផែនការយុទ្ធសាស្ត្រសម្រាប់សាលាដំបូង និងអយ្យការអមសាលាដំបូងក្រុង ភ្នំពេញពីក្រុម ការងារតុលាការគំរូសាលាដំបូងក្រុងភ្នំពេញ កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ ។
- ទទួលលិខិតចាត់តាំងមន្ត្រីជាន់ខ្ពស់ រដ្ឋលេខាធិការអាកាសចរស៊ីវិល ដើម្បីចូលរួមសិក្ខា-សាលាស្តីពីការ ស្ទង់មតិជាមូលដ្ឋាននៃការពង្រឹងអង្គភាពនីតិកម្មនៅតាមក្រសួង កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩
- ទទួលលិខិតចាត់តាំងមន្ត្រីបីរូបពីក្រសួងព័ត៌មាន ដើម្បីចូលរួមសិក្ខាសាលាស្តីពីការស្ទង់ មតិជាមូលដ្ឋាន នៃការពង្រឹងអង្គភាពនីតិកម្មនៅតាមក្រសួង កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៩
- ទទួលលិខិតអញ្ជើញ ពីក្រសួងមហាផ្ទៃ ដើម្បីចូលរួមប្រជុំក្រុមប្រឹក្សាភិបាលជាតិគ្រប់-គ្រងគម្រោងជំនួយ ផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី៣ ដែលកិច្ចប្រជុំនោះ នឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ នៅសណ្ឋាគារសោន់វ៉េ

- ទទួលបានសៀវភៅ “ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ២០០៨-២០១២” ពីក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៩

- ទទួលលិខិតចាត់តាំងមន្ត្រីចំនួន ៣រូប នៃក្រសួងរៀបចំដែនដីនគរូបនីយ៍កម្ម និងសំណង់ ដើម្បីចូលរួម សិក្ខាសាលាស្តីពីការស្ទង់មតិជាមូលដ្ឋាននៃការពង្រឹងអង្គភាព នីតិកម្មនៅតាមក្រសួងកាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩

- ទទួលលិខិតអញ្ជើញ ពីអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជាដើម្បីចូលរួម សិក្ខាសាលាថ្នាក់ជាតិមួយក្រោមអធិបតីភាពរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ស្តីពី “ការប្រឈម និងមេរៀនដែល ទទួលបាន” ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី ២៨ ខែមករា ឆ្នាំ២០០៩ នៅសណ្ឋាគារសាន់វេ ។

- ទទួលរបាយការណ៍ ពីក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅ កម្ពុជានៅដំណាក់កាលទី៣ ប្រចាំត្រីមាសទី៤ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០០៩។

- ផ្ញើលិខិតស្នើសុំទៅតាមក្រសួងនានាដើម្បីចាត់តាំងមន្ត្រីចូលរួមសិក្ខាសាលា ស្តីពីការស្ទង់មតិជាមូលដ្ឋាន នៃការពង្រឹងអង្គភាពនីតិកម្មនៅតាមក្រសួង ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩

- ផ្ញើបាយការណ៍ ជូនអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ស្តីពីវឌ្ឍន-ភាពនៃការអនុវត្តផែនការសកម្មភាពអភិបាលកិច្ចទី២ ប្រចាំឆ្នាំ២០០៨ លើវិស័យកំណែទម្រង់ច្បាប់ និងតុលាការកាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩។

- ផ្ញើលិខិតទៅអគ្គលេខាធិការរង នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយចាត់បញ្ជូនឈ្មោះមន្ត្រីរាជការ ចំនួន១រូប នៃអង្គភាពគ្រប់គ្រងគម្រោងដើម្បីចូលរួមសិក្ខាសាលាស្តីពី Monitoring and Evaluation on ODA Project នៅប្រទេសម៉ាឡេស៊ី ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី០៣-០៥ ខែកុម្ភៈ ឆ្នាំ២០០៩។

- ផ្ញើលិខិតស្នើសុំចាត់តាំងតំណាង ០១ ទទួលបន្ទុកការងារបណ្តឹងប្រជាពលរដ្ឋ និង អធិ-ការកិច្ចរបស់ក្រសួងចូលរួមសិក្ខាសាលាស្តីពី ការសិក្សាបញ្ចូលប្រព័ន្ធ អំប៊ុស្មាន់នៅកម្ពុជា ។

- ផ្ញើលិខិតអញ្ជើញ ចូលរួមប្រជុំក្រុមប្រតិបត្តិគម្រោង សិទ្ធិទទួលបានយុត្តិធម៌ នៅកម្ពុជា ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០០៩ នៅក្រសួងយុត្តិធម៌ ។

- ផ្ញើលិខិតស្នើសុំរៀបចំឯកសារស្តីពីការរៀបចំផែនការសកម្មភាព របស់តុលាការទៅប្រធានសាលាដំបូង រាជធានីភ្នំពេញ ។

- ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលា-ការ នៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០០៩ ។

- ផ្ញើលិខិតស្នើសុំសម្ភាសន៍មន្ត្រីបីរូប ដែលបានចូលរួមសិក្ខាសាលាស្តីពីការរៀបចំ ស្ទង់មតិជាមូលដ្ឋាននៃ ការពង្រឹងអង្គភាពនីតិកម្មនៅតាមក្រសួង កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩ នៅសណ្ឋាគារកាំបូឌីយ៉ាណា ទៅ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

- ផ្ញើលិខិតពន្យាពេល ធ្វើសិក្ខាសាលាស្តីពីការសិក្សាបញ្ចូលប្រព័ន្ធអំប៊ុស្មាន់នៅកម្ពុជា ទៅថ្ងៃ សុក្រ ទី៦ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង ៨ព្រឹក នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់ ។

- ផ្ញើកំណត់បង្ហាញជូនឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល ស្តីពីការកែសម្រួលទៅតាមការណែនាំ របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩។

- ទទួលលិខិតពីអគ្គលេខាធិការរងរាជរដ្ឋាភិបាលអញ្ជើញនាយកអង្គភាពគ្រប់គ្រងគម្រោង ដើម្បីចូលរួម ជាសមាជិកក្នុងពិធីបើកសន្និសីទអ្នកនិពន្ធអក្សរសិល្ប៍ កម្ពុជា-វៀតណាម-ឡាវ លើកទី២ ក្រោមអធិបតីភាព ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩។

- ទទួលលិខិតអញ្ជើញពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចូលរួមកិច្ចប្រជុំស្តីពីវឌ្ឍនភាព ប្រចាំឆ្នាំ ២០០៨ នៃការអនុវត្តក្របខ័ណ្ឌហិរញ្ញប្បទាន សហប្រតិបត្តិការអភិវឌ្ឍន៍នៃប្រព័ន្ធអង្គការសហប្រជាជាតិ ឆ្នាំ ២០០៦-២០១០ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្ពុជា។

- ទទួលលិខិតបញ្ជូនមន្ត្រីចំនួន ០២រូបពី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចូលរួមសិក្ខា សាលាស្តីពីការសិក្សាបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩ ។

- ទទួលលិខិតបញ្ជូនមន្ត្រីចំនួន ០២រូប ពីរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ចូលរួមសិក្ខាសាលា ស្តីពីការសិក្សាបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩។

- ផ្ញើលិខិតជូនឯកឧត្តមអគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីបញ្ជីឈ្មោះសមាជិកចូលរួម ប្រជុំក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ នាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ នៅ សណ្ឋាគារសាន់វ៉េ។

- ផ្ញើលិខិតស្នើសុំលិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់នាយក ប្រធានក្រុមគម្រោង និងអនុប្រធាន ក្រុមគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដើម្បី ចុះហត្ថ-លេខាលើអនុស្សារណៈយោគយល់ គ្នានៃការអនុវត្តគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី៣ នៅខេត្តកំពង់ធំ និងខេត្ត បន្ទាយមានជ័យ ចាប់ពីថ្ងៃទី០៩-១២ ខែមីនា ឆ្នាំ២០០៩។

- ផ្ញើលិខិតស្នើសុំអនុញ្ញាតិជាគោលការណ៍ ដើម្បីរៀបចំសន្និសីទស្តីពី ឯករាជ្យភាពស្ថាប័ន និងសូមគោរព អញ្ជើញឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋ-មន្ត្រី ចូលរួមជាអធិបតីក្នុងកម្មវិធីបើកអង្គសន្និសីទ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី នៅសណ្ឋាគារកាំបូឌីយ៉ាណា។

- ផ្ញើលិខិតស្នើសុំអនុញ្ញាតិជាគោលការណ៍ពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីអញ្ជើញប្រធានតុលាការ និងព្រះរាជអាជ្ញាទូទាំងខេត្ត-ក្រុង មកចូលរួមសន្និសីទស្តីពីឯករាជ្យភាពស្ថាប័ន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៦-២៧ ខែមីនា ឆ្នាំ២០០៩។

- ផ្ញើលិខិតអញ្ជើញអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ ចូលរួមធ្វើផែនការសកម្មភាពតុលាការគំរូ នៅសាលាដំបូងខេត្តបន្ទាយមានជ័យ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ សាលាដំបូង រាជធានីភ្នំពេញ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩

សាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៩ សាលា ដំបូងខេត្តកំពង់ចាម នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ និងសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩។

- ផ្ញើលិខិតស្នើសុំឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃចាត់តាំង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃមួយរូប ដើម្បីបញ្ចូលជាសមាជិកក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

- ផ្ញើលិខិតស្នើសុំលិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់នាយក ប្រធានក្រុមគម្រោង និងអនុប្រធានក្រុមគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីចុះទៅធ្វើផែនការ សកម្មភាពតុលាការគំរូ នៅខេត្តកំពង់ចាម នៅថ្ងៃទី២៥-២៨ ខែមីនា ឆ្នាំ២០០៩។

- ទទួលលិខិតអញ្ជើញពីប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ចូលរួមកិច្ចប្រជុំ ក្រុមប្រឹក្សាភិបាលលើក ទី៩ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាភិបាល នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ នៅ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩។

- ផ្ញើលិខិតស្នើសុំចូលជួបសម្ភាសន៍ជាមួយមន្ត្រីនៅតាមក្រសួងមួយចំនួន ដូចជា ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ ក្រសួងពាណិជ្ជកម្ម ក្រសួងការងារ និង បណ្តុះបណ្តាល វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងការធ្វើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រសួង។

- ផ្ញើលិខិតអញ្ជើញប្រជុំការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២០ មេសា ឆ្នាំ ២០០៩ វេលាម៉ោង ១៤ៈ៣០ នាទីនៅទីស្តីការគណៈរដ្ឋមន្ត្រី។

- ផ្ញើលិខិតស្នើសុំជូនប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីជួបពិភាក្សាស្វែងយល់អំពីការងារ ពាក់ព័ន្ធដល់ការរៀបចំអំប៊ុដ្សមាន់(Ombudsman) នៅកម្ពុជាដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩។

- ផ្ញើលិខិតស្នើសុំជូន ប្រធានគណៈកម្មការទទួលពាក្យបណ្តឹង និងសិទ្ធិមនុស្សនៃរដ្ឋសភាជាតិ ដើម្បីជួបពិភាក្សាស្វែងយល់អំពីការងារពាក់ព័ន្ធដល់ការរៀបចំអំប៊ុដ្សមាន់ (Ombudsman) នៅកម្ពុជាដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០៩។

- បានទទួលលិខិតចាត់តាំង រដ្ឋលេខាធិការមួយរូប ពីក្រសួងមហាផ្ទៃ ដើម្បីបញ្ចូលជាសមាជិកក្រុមប្រឹក្សា កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កាលពីថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០៩។

- បានទទួលរបាយការណ៍បូកសរុបលទ្ធផលអនុវត្តការងារក្នុងខែមករា និងកុម្ភៈ ឆ្នាំ២០០៩ និងទិសដៅ បន្តពីក្រសួងរៀបចំដែនដី នគរូបនីយ៍កម្ម និងសំណង់ កាលពីថ្ងៃទី០២ ខែ មេសា ឆ្នាំ ២០០៩ ។

- បានទទួលលិខិតអញ្ជើញចូលរួមអង្គប្រជុំអន្តរក្រសួង ដោយពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ដែលវិសាលភាពនៃតំបន់អាងទន្លេសាប ដែលបានប្រព្រឹត្តទៅនៅថ្ងៃពុធ ទី ២២ ខែមេសា ឆ្នាំ ២០០៩។

- បានទទួលលិខិតអញ្ជើញចូលរួមអង្គប្រជុំអន្តរក្រសួង ដោយពិភាក្សាបន្តលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការ ត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែន

ទូភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ ដែលបានប្រព្រឹត្តទៅនៅថ្ងៃអង្គារ៍ ទី២១ ខែមេសា ឆ្នាំ២០០៩។

- បានទទួលលិខិតអញ្ជើញ ចូលរួមអង្គប្រជុំអន្តរក្រសួង ដោយពិភាក្សាសេចក្តីព្រាងអនុក្រឹត្យស្តីពីការ បង្កើតនាយកដ្ឋានមួយចំណុះវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃច័ន្ទ ទី២០ ខែមេសា ឆ្នាំ ២០០៩ នឹងបន្តរទៅ ថ្ងៃពុធ ទី២៩ ខែមេសា ឆាំ ២០០៩។

- បានទទួលលិខិតអញ្ជើញ ចូលរួមអង្គប្រជុំអន្តរក្រសួង ដោយពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការ ប្រែក្លាយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការប្រែក្លាយមន្ទីរពេទ្យព្រះកុសុមៈ គ្រឹះស្ថាន ជាសាធារ-ណៈរដ្ឋបាល ដែលបានប្រព្រឹត្តទៅនៅថ្ងៃព្រហស្បត៍ ទី ២៣ ខែមេសា ឆ្នាំ២០០៩។

- បានទទួលលិខិតអញ្ជើញចូលរួមក្នុងពិធីចុះហត្ថលេខាប្រគល់-ទទួលអំណោយសប្បុរស-ជន ជូនមូលនិធិបាយ័ន សម្រាប់កិច្ចការសង្គមកិច្ច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានប្រព្រឹត្តទៅនៅថ្ងៃព្រហស្បត៍ ទី២៣ ខែមេសា ឆ្នាំ ២០០៩។

- បានទទួលរបាយការណ៍ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីលទ្ធផលនៃកិច្ចប្រជុំភាពជាដៃគូ សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ទ្វេភាគីប្រចាំឆ្នាំរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋា-ភិបាលចក្រភពអង់គ្លេស និង សំណើសម្រេចលើជម្រើសសម្រាប់កិច្ចសហប្រតិបត្តិការនាអនាគត កាលពីថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០០៩។

- បានទទួលលិខិតចាត់តាំង មន្ត្រីចូលរៀនវគ្គបណ្តុះបណ្តាលបន្តសម្រាប់ ឆ្នាំ ២០០៩ នៅសាលាភូមិន្ទរដ្ឋបាល

- បានទទួលលិខិតស្នើសុំចាត់តាំងតំណាងចូលរួមប្រជុំ ដើម្បីពិភាក្សាលើការរៀបចំចង-ក្រងផែនការសកម្មភាពអភិបាលកិច្ចទី៣ (២០០៩-២០១២) ពីអគ្គលេខាធិការនៃក្រុមប្រឹក្សា កំណែទម្រង់រដ្ឋបាល។

- បានទទួលលិខិតអញ្ជើញចូលរួមប្រជុំអន្តរក្រសួង ពិភាក្សាលើសេចក្តីព្រាងកម្មវិធី វិនិ-យោគសារណៈ ២០១០-២០១២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃព្រហស្បត៍ ទី៣០ ខែមេសា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០ នាទី។

- បានទទួលលិខិតស្នើសុំអញ្ជើញឯកឧត្តមអគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ពីសាលារាជបណ្ឌិតសភាវិជ្ជជីវៈតុលាការ ដើម្បីផ្តល់បទអន្តរាគមន៍ សិស្សថៅក្រមជំនាន់ទី៥ លើប្រធានបទ ស្តីពី “កំណែទម្រង់ច្បាប់ និងតុលាការ”នៅរសៀលថ្ងៃទី០៦ ខែឧសភាឆ្នាំ២០០៩ នៅរាជបណ្ឌិតសភាវិជ្ជជីវៈ តុលាការ។

- បានទទួលលិខិតពីក្រសួងមហាផ្ទៃ ស្តីពីការចាត់តាំងមន្ត្រីចំនួន ៤ រូប សម្រាប់គម្រោង “ស៊ើបអង្កេត និង ពង្រឹងវិធិសាស្ត្រជាប្រពៃណី នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងកម្មវិធីសកម្មភាព ” កាលពី ថ្ងៃទី២២ ខែ មេសា ឆ្នាំ ២០០៩។

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំការងារជាន់ខ្ពស់គម្រោងតុលាការគំរូ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០០៩ វេលាម៉ោង ១៥ៈ០០ នៅសណ្ឋាគារ អាំងទែកុងទីណង់តាល់។

- ទទួលលិខិតអញ្ជើញជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងសាកលវិទ្យាល័យនាវាចរណ៍កូរ៉េ និងក្រសួងសាធារណៈការនិងដឹកជញ្ជូន ស្តីពីការ

អភិវឌ្ឍន៍ឧស្សាហកម្មផ្នែកនាវាចរនៅកម្ពុជា និងអនុស្សារណៈនៃការយោគយល់គ្នារវាង សាកល-វិទ្យាល័យនាវាចរណ៍កូរ៉េ និងសាកលវិទ្យាល័យពុទ្ធិសាស្រ្ត ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រោមអធិបតីភាពឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្រ្តី រដ្ឋមន្រ្តីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្រ្តី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ២០០៩ ។

- ទទួលលិខិតអញ្ជើញមន្ត្រីជំនាញមួយរូប ចូលរួមជាវាគ្មិនកិត្តិយសក្នុងកម្មវិធី សំណេះ-សំណាលតាមទូរស័ព្ទ ក្នុងកម្មវិធីមាគ៌ាច្បាប់នៅកម្ពុជា របស់វិទ្យុFM១០២ នៃមណ្ឌលព័ត៌មានស្ត្រីកម្ពុជា ក្នុងកម្មវិធីសំណេះសំណាល ក្រោមប្រធានបទ “តុលាការគំរូ ” នៅថ្ងៃព្រហស្បត៍ទី ២១ ខែឧសភា ឆ្នាំ ២០០៩។

- ទទួលលិខិតអញ្ជើញពីនាយកដ្ឋានសវកម្មផ្ទៃក្នុងដើម្បីសុំចុះព័ត៌មាន និងធ្វើសវនកម្មនៅក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ សម្រាប់កាលបរិច្ឆេទ ២០០៧-២០០៨ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០០៩ វេលាម៉ោង ៨:៣០ នាទីព្រឹក។

- ទទួលរបាយការណ៍ពីអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ស្តីពីកិច្ចប្រជុំអន្តរក្រសួង ដើម្បីរៀបចំចងក្រងផែនការសកម្មភាពអភិបាលកិច្ចទី (២០០៩-២០១៣)។

- ទទួលលិខិតអញ្ជើញចូលរួមអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើ សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសេចក្តីព្រាងស្តីពីការប្រែក្លាយមន្ទីរពេទ្យព្រះកុសុមៈ គ្រឹះស្ថានជាសាធារណៈរដ្ឋបាល ដែលនឹងប្រព្រឹត្ត ទៅ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៦-២៧ខែ ឧសភា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី។

- ទទួលរបាយការណ៍ពីអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដោយអញ្ជើញតំណាង ក្រសួងនិងក្រុមការងារចូរួមប្រជុំ ដើម្បីពិភាក្សាលើការរៀបចំ ចងក្រងផែនការសកម្មភាពអភិបាលកិច្ចទី៣ (២០០៩-២០១៣ ) ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង ១៥:០០ រសៀលនៅ សាល ប្រជុំទីស្តីការគណៈរដ្ឋមន្ត្រី។

- ទទួលលិខិតអញ្ជើញជាកិត្តិយស ក្នុងពិធីទទួលជួបឯកឧត្តម ពិលល ្រាមមលេល រដ្ឋមន្ត្រីក្រសួងការបរទេស អង់គ្លេស ក្រោមអធិបតីរបស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០០៩ វេលាម៉ោង ១១:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

- ធ្វើសេចក្តីសម្រេចលេខ ០៣៥/០៩ សរ.កកចយ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០០៩ “ សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ សម្រាប់កំណែ ទម្រង់ច្បាប់ និងតុលាការ ។

- ធ្វើលិខិតលេខ ០៣៩/០៩ លអ.កកចយ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ អញ្ជើញចូលរួមប្រជុំក្រុមប្រឹក្សាគម្រោងសិទ្ធិទទួលបានយុត្តធម៌នៅកម្ពុជា នៅថ្ងៃអង្គារ៍ទី ២៥ ខែសីហា ឆ្នាំ២០០៩។

- ធ្វើលិខិតជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្តីពីការស្នើសុំឯកសារសង្ខេបពាក់ព័ន្ធ នឹងជំនួយរបស់រដ្ឋាភិបាលបារាំងកន្លងមក និងសំណូមពរដែលចង់អោយ រដ្ឋាភិបាលបារាំងផ្តល់ជំនួយបន្ត។

- ផ្ញើលិខិតជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឯកឧត្តម ទេព ដារ៉ុង ប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឯកឧត្តម ជីវ កេង ប្រធានសាលាដំបូងរាជធានីភ្នំពេញ និងឯកឧត្តម ឧត្តមសេនីយ៍ឯក សៅ សុខា អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សំណើសុំត្រៀមបទ អន្តរាគមន៍ ស្តីពីសមិទ្ធិផលនានាដែលពាក់ព័ន្ធ និងការកែទម្រង់ច្បាប់ និងតុលាការ និងឯកសារមួយចំនួនសម្រាប់ធ្វើការផ្សព្វផ្សាយ។

- ផ្ញើលិខិតអញ្ជើញក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៩។

- ទទួលលិខិតលេខ ៩០៧ សជណ.រប ចុះថ្ងៃទី ០១ ខែកក្កដាឆ្នាំ ២០០៩ ស្តីពីការផ្លាស់ប្តូរថ្ងៃ និងពេលវេលាទទួលដំណើរមាតុភូមិនិវត្តន៍ របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈមន្ត្រី និងលោក ជំទាវព្រមទាំងប្រតិភូមកពីប្រទេសអេស្ប៉ាញ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៤៥ នាទី (យន្តហោះចុះចត) នោះត្រូវបានលើកទៅថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៤៥ នាទី (យន្តហោះចុះចត ) វិញ។

- ទទួលលិខិតអញ្ជើញចូលរួមប្រជុំងអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើត នាយកដ្ឋានសវនកម្មផ្ទៃក្នុងនិងនាយកដ្ឋានសហប្រតិបត្តិការ អន្តរជាតិនៃក្រសួង ធម្មការ និងសាសនាដែលនឹងប្រព្រឹត្ត ទៅនៅថ្ងៃពុធទី ២៤ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០ នាទីនៅទីស្តីការគណៈរដ្ឋមន្ត្រី។

- ទទួលលិខិតអញ្ជើញចូលរួមអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងសេចក្តីថ្លែងការណ៍ របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃព្រហស្បត៍ទី ២៥ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០ នាទី នៅទីស្តីការគណៈមន្ត្រី។

- ទទួលលិខិតអញ្ជើញចូលរួមជាភ្ញៀវកិត្តយស ក្នុងពិធីប្រកាសតែងតាំង និងចូលកាន់តំណែងអគ្គព្រះរាជ អាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ និងក្នុងពិធីប្រកាសតែងតាំង និងចូលកាន់តំណែងអគ្គព្រះរាជអាជ្ញានៃ មហាអយ្យការអមតុលាការកំពូលថ្ងៃព្រហស្បត៍ ទី ២៥ ខែមិថុនា ឆ្នាំ ២០០៩ វេលាម៉ោង ១៤ៈ៣០ នាទី ។

## ខ. ការងារកំណែទម្រង់

- រៀបចំកិច្ចប្រជុំ ក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩ នៅ សាលប្រជុំក្រសួងយុត្តិធម៌ នៅសាលប្រជុំក្រសួងយុត្តិធម៌ ។

- ចូលរួមអង្គប្រជុំលើកទី១ ដោយពិភាក្សាបន្តលើ (១)សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកែសម្រួលមាត្រា១ និងមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និង (២)សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃពុធ ទី២៨ ខែមករា ឆ្នាំ២០០៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

- រៀបចំសិក្ខាសាលាស្តីពីការស្ទង់មតិជាមូលដ្ឋាននៃការពង្រឹងអង្គភាពនីតិកម្ម នៅតាមក្រសួងដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩ នៅសណ្ឋាគារកាំបូឌីយ៉ាណា។

- រៀបចំកិច្ចប្រជុំ ក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ នៅសាលប្រជុំក្រសួងយុត្តិធម៌។

- រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០០៩ វេលាម៉ោង ១៤:៣០នាទី នៅសណ្ឋាគារសាន់វ៉េ។

- ចូលរួមកិច្ចប្រជុំ ស្តីពីការស្ទង់មតិក្នុងការពង្រឹងសមត្ថភាពនីតិកម្មនៅតាមក្រសួង ដោយជួបជាមួយនឹង ក្រសួងពាក់ព័ន្ធមួយចំនួនដូចជា ៖ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួង ពាណិជ្ជកម្ម ក្រសួងអប់រំ យុវជន និងកីឡា។

- ចូលរួមប្រជុំជាមួយនឹង CCJAPIII និង EWMI ស្តីពីតុលាការគំរូ នៅថ្ងៃទី៧ ខែកុម្ភៈ និងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩។

- ចូលរួមប្រជុំ ជាមួយក្រុមការងារតុលាការគំរូខេត្តកណ្តាលស្តីពីតុលាការ គំរូនៅថ្ងៃទី៦ខែកុម្ភៈ ឆ្នាំ២០០៩។

- បានរៀបចំ ឯកសារសម្រាប់ធ្វើបទបង្ហាញ ស្តីពីភាពជឿនលឿននៃការអនុវត្តកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅពេលប្រជុំពិគ្រោះយោបល់ទ្វេភាគីថ្នាក់ជាន់ខ្ពស់រវាងរដ្ឋា ភិបាលកម្ពុជា និងប្រទេសដាណឺម៉ាក់ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ និងរវាងកម្ពុជា និងចក្រភពអង់គ្លេស នៅថ្ងៃ ទី១៩ ខែមីនា ឆ្នាំ២០០៩។

- បានជួបជាមួយលោកស្រី Maria Rasmussen មកពី DIHR (Danish Institute for Human Right) ដើម្បីពិភាក្សាពីបញ្ហាកិច្ចសន្ទនារវាងរដ្ឋ និងសង្គមស៊ីវិល។

- បានចូលរួមធ្វើផែនការសកម្មភាពតុលាការគំរូ នៅតាមបណ្តាខេត្តមួយចំនួន ដូចជា: សាលាដំបូងខេត្ត បន្ទាយមានជ័យ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩, សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩, សាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៩, សាលាដំបូងខេត្តកំពង់ចាម នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ និងសាលាដំបូង រាជធានីភ្នំពេញ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩។

- បានរៀបចំ សិក្ខាសាលាស្តីពីការសិក្សាបញ្ចូលប្រព័ន្ធអំប៊ុដ្សមាន់នៅកម្ពុជា នៅថ្ងៃសុក្រ ទី៦ ខែមីនាឆ្នាំ ២០០៩ វេលាម៉ោង ៨ព្រឹក នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។

- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ នៅទីស្តីការ គណៈរដ្ឋមន្ត្រីនាថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ។

- បានជួបពិភាក្សាស្វែងយល់អំពីការងារពាក់ព័ន្ធដល់ការរៀបចំអំប៊ុដ្សមាន់ (Ombudsman) នៅកម្ពុជាជា មួយនឹងក្រសួងស្ថាប័នមួយចំនួន ។

- បានរៀបចំកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់គម្រោងតុលាការគំរូ នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៩ វេលា ម៉ោង ១៥:០០ រសៀលនៅសណ្ឋាគាអាំងទែរកុងទីណង់តាល់ ។

- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ កាលពីថ្ងៃច័ន្ទ ទី ១៥ ខែមិថុនា ឆ្នាំ២០០៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

- អង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានរៀបចំកិច្ចប្រជុំមួយ ដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយអនុប្រធានឧត្តមក្រុម ប្រឹក្សាសារការីប្រទេស

បារាំង និងរាជបណ្ឌិតសភា វិជ្ជាជីវៈតុលាការ ក្រោមអធិបតីភាពឯកឧត្តម ស៊ុយ ម៉ុង លាង អគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌កាលពីថ្ងៃពុធ ទី១៥ ខែមិថុនា ឆ្នាំ ២០០៩ ។

- កិច្ចប្រជុំផ្ទៃក្នុងដឹកនាំដោយឯកឧត្តម ស៊ុយ ម៉ុងលាង អគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌ ស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ដើម្បីអនុវត្តសារាចររបស់ រាជរដ្ឋាភិបាលនាថ្ងៃពុធទី២៤ ខែមិថុនា ឆ្នាំ២០០៩ និងបានធ្វើសេចក្តីសម្រេចលេខ:០៣៥/០៩ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្ន ២០០៩-២០១៣ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ។

- ក្រុមគម្រោងនីមួយៗ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានរៀបចំ និងធ្វើផែនការ ការងារសម្រាប់ឆ្នាំ ២០០៩។

## គ. ផ្សេងៗ

- ចូលរួមប្រជុំអន្តរក្រសួង

- ចូលរួមប្រជុំអន្តរក្រសួង ដោយពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូចមូលបត្រមហាជន នៅថ្ងៃទី១៧-១៨-១៩ ខែកុម្ភៈ ឆ្នាំ២០០៩

- ចូលរួមប្រជុំអន្តរក្រសួង ស្តីពីសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកែសម្រួលមាត្រា ១ និងមាត្រា ៦ នៃ ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែ ទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងស្តីពីសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

- ចូលរួមសិក្ខាសាលាជាតិ ស្តីពីការផ្សព្វផ្សាយទិសដៅយុទ្ធសាស្ត្រនៃកម្មវិធីជាតិ កំណែទម្រង់រដ្ឋបាល និង ការរៀបចំផែនការសកម្មភាព សម្រាប់ឆ្នាំ២០០៩-២០១៣ នៅថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០០៩ សណ្ឋាគារ អាំងទែរកុងទីណង់តាល់។

- ចូលរួមកិច្ចប្រជុំអន្តរក្រសួងពិភាក្សា និងប្រមូលផ្តុំមតិក្នុងការរៀបចំចងក្រងសេចក្តីព្រាងផែនការសកម្មភាពអភិបាលកិច្ចទី៣ (២០០៩-២០១៣) នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៩។

- ចូលរួមកិច្ចប្រជុំអន្តរក្រសួងពិភាក្សា និងប្រមូលផ្តុំមតិក្នុងការរៀបចំចងក្រងសេចក្តីព្រាងផែនការសកម្មភាពអភិបាលកិច្ចទី៣ (២០០៩-២០១៣) នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៩។

## ២-សន្និដ្ឋាន

ចាប់ពីខែ មករា ដល់ខែមិថុនាឆ្នាំ២០០៩ នេះក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានរៀបចំកិច្ចប្រជុំក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅ កម្ពុជាចំនួនបីលើក: លើកទី១នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩ នៅសាលប្រជុំក្រសួងយុត្តិធម៌ ដើម្បីពិនិត្យ និងសម្រេចលើរបាយការណ៍ប្រចាំឆ្នាំ២០០៨ ស្តីពីសមិទ្ធផលដែលទទួលបាន និងផែនការសកម្មភាពសម្រាប់រយៈ ពេលបន្តដល់ចុងឆ្នាំ២០០៩ លើកទីពីរនៅថ្ងៃទី១៧ ខែកុម្ភៈឆ្នាំ២០០៩ និងលើទីបីនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ដោយផ្តោតទៅ

លើភាពរីកចម្រើននៃការអនុវត្តគម្រោងក្នុងត្រីមាសទី១ និងត្រីមាសទី២ និងអំពីសំណើកែតម្រូវផែនការសកម្មភាព និងថវិការឆ្នាំ២០០៩។

- ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយិត្តិធមិបានរៀបចំសិក្ខាចំនួនបីលើៈលើកទី១ អង្គភាពគ្រប់គ្រងគម្រោង បានសហាការជាមួយនឹងអង្គការអាល្លឺម៉ង់ GTZ ដើម្បីរៀបចំសិក្ខា-សាលាមួយស្តីពីការស្ទង់មតិជាមូលដ្ឋាន នៃការពង្រឹងអង្គភាពនីតិកម្មនៅតាមក្រសួង ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩នៅសណ្ឋាគារ កាំបូឌីយ៉ាណាដើម្បីប្រមូលនូវព័ត៌មាន និងអនុសាសន៍ដោយទទួលបាននូវលទ្ធផលពីគ្រប់បណ្តាក្រសួងពាក់ព័ន្ធ និងបានធ្វើការចុះជួបជាមួយនឹងមន្ត្រីអង្គភាពនីតិកម្មនៅតាមក្រសួង ស្ថាប័នមួយចំនួន លើកទីពីរក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិក៏បានរៀបចំសិក្ខា ស្តីពីការបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅ កម្ពុជានៅថ្ងៃទី ០៦ ខែមិនា ឆ្នាំ២០០៩ វេលាម៉ោង៨ៈ០០ ព្រឹកនៅសណ្ឋាគារអាំងទែកុងទីណង់តាល់ដោយមានការឧបត្ថម្ភពីកិច្ចសហ ប្រតិបត្តិការបរទេសអាឡឺម៉ង់នៃកម្មវិធីកំណែទម្រង់រដ្ឋបាលនិងវិមជ្ឈការ ។

- លើទីបីក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិបានរៀបចំកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់គម្រោងតុលាការគំរូនៅ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង ១៥ៈ០០ រសៀលនៅសណ្ឋាគារអាំងទ័រកុងទីណង់តាល់ ដោយមានការចូលរួម ពីតំណាងក្រុមការងារតុលាការគំរូទាំងបួនគឺៈ សាលាដំបូងក្រុងភ្នំពេញ សាលាដំបូងខេត្តកណ្តាល សាលាដំបូងបន្ទាយមានជ័យ និងសាលាដំបូងខេត្តកំពង់ចាមដោយបានពិភាក្សា និងការអនុម័តលើផែនការយុទ្ធសាស្រ្តរបស់តុលាការគំរូទាំងបួនខេត្តក្រុង ។

- ក្នុងរយៈកាលប្រាំមួយខែដើមឆ្នាំនេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធមិបានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការចំនួនបីលើកៈ លើទី១ នៅ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ វេលាម៉ោង ១៤ៈ៣០នាទី នៅសណ្ឋាគា សាន់វ៉េ លើទីពីរនៅទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី២០ ខែ មេសាឆ្នាំ២០០៩ ដោយលើកយករបាយការណ៍ភាពជឿនលឿននៃសូចនាករតាមដានរួម (JMIs) លើទីបីនៅ ថ្ងៃច័ន្ទទី១៥ ខែមិថុនា ឆ្នាំ២០០៩ នៅទីស្តីការគណៈរដ្ឋមន្ត្រីវេលាម៉ោង ១៤ៈ៣០នាទី ជាមួយស្ថាប័នពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍ ដោយផ្តោតទៅលើគម្រោងតុលាការគំរូ និងការពិភាក្សាអំពីការផ្ទេរគម្រោង តុលាការគំរូដែលស្ថិតនៅក្នុងគម្រោងរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិទៅក្នុងគម្រោងរបស់ក្រសួងយុត្តិធមិ និងអំពីការស្នើសុំថវិការបន្ថែមដោយក្រសួងយុត្តិធមិសម្រាប់ ការរៀបចំផែនការយុទ្ធសាស្រ តុលាការគំរូទាំងបួន និងលើកទីបួនដែលនិងត្រូវធ្វើឡើងនៅថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០៩ នេះ ។

## ៣-ទិសដៅអនុវត្តក្នុងឆមាស ឆ្នាំ២០០៩

- ក្នុងរយៈកាលប្រាំមួយខែដើមឆ្នាំនេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធមិបានរៀបចំកិច្ចប្រជុំ ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការចំនួនបីលើកៈ លើទី១ នៅនៅថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ២០០៩ វេលាម៉ោង ១៤ៈ៣០នាទី នៅសណ្ឋាគា សាន់វ៉េ លើទីពីរនៅទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ២០ ខែមេសាឆ្នាំ២០០៩ ដោយលើកយករបាយការណ៍ភាពជឿនលឿននៃសូចនាករតាមដានរួម (JMIs)លើទីបីនៅ ថ្ងៃច័ន្ទទី១៥ ខែមិថុនា ឆ្នាំ២០០៩ នៅ ទីស្តីការគណៈរដ្ឋមន្ត្រីវេលាម៉ោង ១៤ៈ៣០នាទី ជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ដោយផ្តោតទៅលើគម្រោងតុលាការគំរូ និងការពិភាក្សាអំពីការផ្ទេរគម្រោង តុលាការគំរូ

ដែលស្ថិតនៅ ក្នុងគម្រោងរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ទៅក្នុងគម្រោងរបស់ក្រសួងយុត្តិធម៌ និងអំពីការស្នើសុំថវិកាបន្ថែមដោយក្រសួងយុត្តិធម៌សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រ តុលាការគំរូទាំងបួន និងលើកទីបួនដែលនិងត្រូវធ្វើឡើងនៅថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០៩ នេះ ។

**៣-និសដៅអនុវត្តក្នុងឆមាស ឆ្នាំ២០០៩**

- រៀបចំប្រជុំគណៈកម្មាធិការអនុម័តមូលនិធិបត់បែនរបស់គម្រោង CCJAPIII
- ពិភាក្សាជាមួយ DIHR ពីកិច្ចព្រមព្រៀងរវាងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និង DIHR សម្រាប់ឆ្នាំ២០០៩
- រៀបចំព្រះរាជក្រឹត្យតែងតាំងសមាជិកក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ថ្មី និងព្រះរាជក្រឹត្យ អនុក្រឹត្យតែងតាំងបុគ្គលិកអគ្គលេខាធិការដ្ឋានជាថ្មី។
- រៀបចំពិភាក្សាជាមួយក្រុមពិភាក្សាយោបល់ CCJAP
- ត្រៀមរៀបចំ National Management Board CCJAP
- បន្តអនុវត្តគម្រោងតុលាការគំរូ
- បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ
- បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន
- បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ GTZ
- រៀបចំក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ
- រៀបចំប្រជុំក្រុមប្រឹក្សាប្រតិបត្តិគម្រោងលទ្ធភាពទទួលបានយុត្តិធម៌
- ត្រៀមរៀបចំសន្និសិទជាតិស្តីពីលទ្ធផលការងារសំខាន់ៗពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០០៨

រាជធានីភ្នំពេញ, ថ្ងៃទី ខែមិថុនាឆ្នាំ២០០៩

**អ្នកធ្វើរបាយការណ៍**

**ស៊ុន សិរីវុធ**

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

**ស៊ុយ ម៉ុងលាង**